**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**វិទ្យាស្ថានជាតិអប់រំ**

**លេខ ...៧៦៦...វជអ.**

# បទបញ្ជាផ្ទៃក្នុង

## សម្រាប់គ្រូឧទ្ទេស និងមន្ត្រីបំពេញការងារនៅក្នុង មជ្ឈមណ្ឌលស្រាវជ្រាវគរុកោសល្យជំនាន់ថ្មី (មសគថ)

**យោង៖**-ប្រកាសលេខៈ ១៨៦៦ អយក.ប្រក ចុះថ្ងៃសុក្រ ១កើត ខែភទ្របទ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣ ត្រូវនឹងថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១៩ របស់ក្រសួងអប់រំ យុវជន និងកីឡា ស្តីពីការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់អប់រំ ឯកទេសប្រឹក្សាគរុកោសល្យនៅវិទ្យាស្ថានជាតិអប់រំ។

- លទ្ធផលជ្រើសរើសនិស្សិតចូលចូលសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់អប់រំ ឯកទេសប្រឹក្សាគរុកោសល្យ នៅវិទ្យាស្ថានជាតិអប់រំ ឆ្នាំសិក្សា២០១៩-២០២០ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១៩

ដើម្បីឱ្យដំណើរការបណ្តុះបណ្តាល មានភាពរលូន និងមានប្រសិទ្ធភាព សូមធ្វើការណែនាំដល់ថ្នាក់ដឹកនាំ គ្រូឧទ្ទេស និងមន្ត្រីដែលអញ្ជើញមកបំពេញការងារនៅក្នុងមជ្ឈមណ្ឌលស្រាវជ្រាវគរុកោសល្យជំនាន់ថ្មីដូចខាងក្រោម៖

**ប្រការ១:** **គោលបំណង**

បទបញ្ជាផ្ទៃក្នុងនេះ មានគោលបំណងដើម្បីរួមចំណែក ក្នុងការរៀបចំដំណើរការនៃការបង្រៀន និងជំរុញមនសិកាវិជ្ជាជីវៈរបស់លោកគ្រូ អ្នកគ្រូដែលជាគ្រូឧទ្ទេស ព្រមទាំងការសិក្សារបស់គរុនិស្សិតឲ្យទទួលបានគុណភាព និងមានប្រសិទ្ធភាពខ្ពស់ ព្រមទាំងការអប់រំ គុណធមិ និង សីលធមិ ដែលជាកត្តាដ៏សំខាន់ក្នុងការលើកស្ទួយវិស័យអប់រំ ដើម្បីរួមចំណែកក្នុងការអភិវឌ្ឍធនធានមនុស្សនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ២:** **វិសាលភាព**

បទបញ្ជាផ្ទៃក្នុងនេះ សម្រាប់អនុវត្តចំពោះលោកគ្រូ អ្នកគ្រូជាគ្រូឧទ្ទេស ដែលបំពេញការងារក្នុងមជ្ឈមណ្ឌលស្រាវជ្រាវគរុកោសល្យជំនាន់ថ្មីតែប៉ុណ្ណោះ។

**ប្រការ៣:** គ្រូឧទ្ទេស នឹងត្រូវទទួលការវាយតម្លៃការបង្រៀនរបស់ខ្លួនដោយគរុនិស្សិត ក្នុងថ្នាក់ និងពីគណៈគ្រប់គ្រងមជ្ឈមណ្ឌល។



អាសយដ្ឋានលេខ ១២៣ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ៖ (៨៥៥-២៣) ២១៥/៥៨៤ គេហទំព័រ៖ www.nie.edu.kh

**ប្រការ៤:** លោកគ្រូ អ្នកគ្រូឧទ្ទេសត្រូវមានសេចក្តីព្យាយាម អំណត់អត់ធ្មត់ ប្តូរផ្តាច់ និងមានទំនួលខុសត្រូវក្នុងការបំពេញភារកិច្ចរបស់ខ្លួន ដែលគណៈគ្រប់គ្រងមជ្ឈមណ្ឌលបានប្រគល់ជូន។

**ប្រការ៥:** គ្រូឧទ្ទេសត្រូវរៀបចំចរិយាសម្បត្តិឲ្យបានសមរម្យ ថ្លៃថ្នូរ សុភាពរាបសា មធ្យ័តជាគំរូល្អ សម្រាប់គរុនិស្សិតគ្រប់រូប។ លោកគ្រូ អ្នកគ្រូ ត្រូវពាក់បណ្ណសម្គាល់ខ្លួននៅពេលចូលក្នុងបរិវេណមជ្ឈមណ្ឌល។

**ប្រការ៦:** គ្រូឧទ្ទេសត្រូវមកបង្រៀនឲ្យបានទៀងទាត់ពេលវេលា តាមពេលម៉ោងកំណត់ឲ្យបានម៉ត់ចត់ បង្រៀនឲ្យគ្រប់ម៉ោង ដោយធានាឲ្យបានជាដាច់ខាត ចំពោះប្រសិទ្ធភាព និងគុណភាពនៃការបង្រៀន។ ការសុំច្បាប់ដោយមានធុរៈចាំបាច់លោកគ្រូ អ្នកគ្រូ ត្រូវសុំច្បាប់ជាលាយលក្ខណ៍អក្សរមកគណៈគ្រប់គ្រងមជ្ឈមណ្ឌលឲ្យបានមុនយ៉ាងតិច១ថ្ងៃ។

**ប្រការ៧:** គ្រូឧទ្ទេសត្រូវរៀបចំសៀវភៅរដ្ឋបាលដូចជា បញ្ជីហៅឈ្មោះគរុនិស្សិត បញ្ជីស្រង់ពិន្ទុគរុនិស្សិត សៀវភៅតាមដានការសិក្សា សៀវភៅកិច្ចតែងការបង្រៀន សៀវភៅទទួល និងបែងចែកសម្ភារ។

**ប្រការ៨:** គ្រូឧទ្ទេស ត្រូវរៀបចំឲ្យមានកិច្ចតែងការបង្រៀន ដែលសមស្រប ទៅតាមច្បាប់គរុកោសល្យ ព្រមទាំងមានសម្ភារឧបទេស ឲ្យត្រូវតាមខ្លឹមសារមេរៀននីមួយៗនៅពេលបង្រៀន។ ត្រូវដាក់កិច្ចការឱ្យគរុនិស្សិតធ្វើ និងត្រួតពិនិត្យកែកិច្ចការនោះជាប្រចាំ។ ប្រសិនបើគរុនិស្សិត មិនធ្វើកិច្ចការទេនោះ គ្រូឧទ្ទេស ត្រូវចាត់វិធានការជាបន្ទាន់ទៅតាមបទបញ្ជាផ្ទៃក្នុងរបស់គរុនិស្សិត។ គ្រូឧទ្ទេស ត្រូវប្រឹងប្រែងឲ្យអស់ពីសមត្ថភាព ដើម្បីផ្តល់គុណភាពសិក្សា អប់រំតាមនិយាមគរុកោសល្យដល់គរុនិស្សិត។

**ប្រការ៩:** គ្រូឧទ្ទេស និងមន្ត្រី ត្រូវចូលរួមចំណែកក្នុងការថែរក្សាទ្រព្យសម្បត្តិរបស់មជ្ឈមណ្ឌលដូចជាការប្រើប្រាស់សម្ភារបរិក្ខារសិក្សាផ្សេងៗ រួមមានៈ តុ-កៅអី សម្ភារឧបទេស សម្ភារពិសោធ កុំព្យូទ័រ វិដេអូ សៀវភៅសិក្សា។ល។ និងរួមចំណែកសន្សំសំចៃការប្រើប្រាស់ ទឹក ភ្លើង ជាដើម។

**ប្រការ១០:** គ្រូឧទ្ទេស និងមន្ត្រី ត្រូវចូលរួមសកម្មភាពផ្សេងៗ តាមការតម្រូវរបស់មជ្ឈមណ្ឌលដូចជា ចូលរួមសន្និសីទ សិក្ខាសាលា សកម្មភាពស្រាវជ្រាវ ការប្រជុំពាក់ព័ន្ធ នឹងការអភិវឌ្ឍកម្មវិធីសិក្សា ការចូលរួមត្រួតពិនិត្យ ការប្រឡងនានា ព្រមទាំងសកម្មភាពសង្គមមួយចំនួន តាមការចាំបាច់ជាក់ស្តែង។

**ប្រការ១១:** គ្រូឧទ្ទេស ត្រូវបំពេញកាតព្វកិច្ចរបស់ខ្លួន ក្នុងការផ្តល់ពិន្ទុប្រឡងគ្រប់ប្រភេទ និងឯកសារស្រាវជ្រាវផ្សេងៗរបស់គរុនិស្សិតមកគណៈគ្រប់គ្រងមជ្ឈមណ្ឌលឲ្យបានទាន់ពេលវេលាកំណត់ និងធានាបាននូវសុក្រិត្យភាព។

**ប្រការ១២:** គ្រូឧទ្ទេស និងមន្ត្រីត្រូវបង្កើតទំនាក់ទំនងល្អ ជាមួយគណៈគ្រប់គ្រងគ្រប់លំដាប់ថ្នាក់ ដោយឈរលើស្មារតីសម្របសម្រួល និងអធ្យាស្រ័យគ្នាក្នុងការដោះស្រាយរាល់បញ្ហា។

**ប្រការ១៣:** គ្រូឧទ្ទេស និងមន្ត្រី បំពេញការងារនៅក្នុងមជ្ឈមណ្ឌលទាំងអស់ ត្រូវមានវិន័យនិងប្រកាន់ខ្ជាប់នូវ ក្រមសីលធម៌វិជ្ជាជីវៈ គ្រូបង្រៀននិងត្រូវអនុវត្តឲ្យបានម៉ឺងម៉ាត់។

**ប្រការ១៤**: ក្នុងការបង្រៀន គ្រូឧទ្ទេសត្រូវជ្រះថ្លាក្នុងការលើកយកខ្លឹមសារលើប្រធានបទ ឬមុខវិជ្ជា ដែលត្រូវបង្រៀន ព្រមទាំងខ្លឹមសារ ឬប្រធានបទពាក់ព័ន្ធផ្សេងទៀតមកពន្យល់ អត្ថាធិប្បាយបំពេញបន្ថែមឱ្យបានស៊ីជម្រៅ។

**ប្រការ១៥**: គ្រូឧទ្ទេស និងមន្ត្រីត្រូវប្រកាន់ខ្ជាប់នូវឥស្សរភាពវិជ្ជាជីវៈដែលមានជាអាទិ៍ៈឯករាជ្យ សេរីភាព និង ឧត្តមភាពក្នុងពេលបំពេញការងាររបស់ខ្លួន។

**ប្រការ១៦**: គ្រូឧទ្ទេសត្រូវមានការប្រុងប្រយ័ត្នក្នុងការនិយាយស្តី និងគិតដល់ពាក្យសម្តីរបស់ខ្លួន ចំពោះគរុនិស្សិតនិងសាធារណជន ក្នុងការផ្តល់ព័ត៌មានអំពីការអប់រំ ទាំងសាធារណៈ និងឯកជន។

**ប្រការ១៧**: គ្រូឧទ្ទេស ឬមន្ត្រី មិនត្រូវធ្វើការរៃអង្គាសប្រាក់ ប្រមូលប្រាក់ក្រៅផ្លូវការ ឬធ្វើអាជីវកម្មនានាក្នុងបរិវេណមជ្ឈមណ្ឌលឡើយ។

**ប្រការ១៨**: គ្រូឧទ្ទេសមិនត្រូវធ្វើអ្វីដែលនាំឲ្យប៉ះពាល់ ឬខូចខាតដល់គុណភាពអប់រំ នៅក្នុងពេលបំពេញការងាររបស់ខ្លួន ទោះបីតាមរូបភាពបែបណាក៏ដោយ។

**ប្រការ១៩**: គ្រូឧទ្ទេស និងមន្ត្រី មិនត្រូវពាក់ព័ន្ធនឹងចលនា ឬនិន្នាការនយោបាយណាមួយឡើយ ហើយពិសេសមិនត្រូវនិយាយពាក្យសំដីណាដែលនាំឱ្យប៉ះពាល់ដល់ការដឹកនាំរបស់រាជរដ្ឋាភិបាលជាដាច់ខាត។

**ប្រការ២០**: ករណីគ្រូឧទ្ទេស ឬមន្ត្រី រូបណាមិនបានប្រតិបត្តិតាមបទប្បញ្ញត្តិទាំងឡាយ ដូចបានកំណត់ខាងលើនេះ ត្រូវទទួលរងការដាក់ពិន័យពីមជ្ឈមណ្ឌលមានជាអាទិ៍: វិន័យរដ្ឋបាល ការស្តីបន្ទោសផ្ទាល់មាត់ ការស្តីបន្ទោសជាលាយលក្ខណ៍អក្សរ ការដកម៉ោងបង្រៀន ឬការកាត់ប្រាក់កម្រៃពីការបង្រៀនជាដើម។ល។

**ប្រការ២១**: ករណីបំពានធ្ងន់ធ្ងរលើបទប្បញ្ញត្តិណាមួយនៃបទបញ្ជាផ្ទៃក្នុងនេះ ត្រូវធ្វើការវិនិច្ឆ័យសម្រេច ដោយក្រុមប្រឹក្សាវិន័យរបស់មជ្ឈមណ្ឌល នឹងត្រូវបញ្ចប់កិច្ចសន្យាការងារ ឬប្រគល់ជូនអាជ្ញាធរ មានសមត្ថកិច្ចដោះស្រាយតាមផ្លូវច្បាប់។

**ប្រការ២២**: **ការផ្សព្វផ្សាយ**

បទបញ្ជាផ្ទៃក្នុងនេះ ត្រូវប្រជុំផ្សព្វផ្សាយដល់គ្រូឧទ្ទេស មន្ត្រី អ្នកពាក់ព័ន្ធ និងបិទផ្សាយជា សាធារណៈ។

**ប្រការ២៣**: **ការអនុវត្ត**

គ្រូឧទ្ទេស និងមន្ត្រី ដែលបំពេញការងារនៅមជ្ឈមណ្ឌលស្រាវជ្រាវគរុកោសល្យជំនាន់ថ្មីទាំងអស់ ត្រូវគោរព និងអនុវត្ត បទបញ្ជាផ្ទៃក្នុង នេះដោយមានការទទួលខុសត្រូវ និងឲ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃព្រហស្បតិ៍ ១៣រោច ខែភទ្របទ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០១៩

**នាយកវិទ្យាស្ថានជាតិអប់រំ**

**បណ្ឌិត.សៀង សុវណ្ណា**

ចម្លងជូនៈ
- ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី
- អង្គការសេកម្មភាពសម្រាប់ការអប់រំនៅកម្ពុជា "ដើម្បីជូនជ្រាបជាព័ត៌មាន"
- គណៈគ្រប់គ្រងមជ្ឈមណ្ឌល គ្រូឧទ្ទេស "ដើម្បីជ្រាបនិងអនុវត្ត"
- កាលប្បវត្តិ- ឯកសារ វជអ.